ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤៥ ព.ណ.ន/ពា.ប្រក

# ប្រកាស
## ស្តីពីការធ្វើប្រតិភូកម្មការងារគ្រប់គ្រងសកម្មភាពអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ជូនដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខនស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពផលិតផលទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ៩១អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ២៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាល នៅថ្នាក់ក្រោមជាតិ

-ប្រកាសរួមលេខ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

-ប្រកាសរួមលេខ៩៨៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

-យោងតាមលិខិតលេខធ៩.០៩.៥៩៨ សជណ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការរបស់ធនាគារជាតិនៃកម្ពុជា

-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១ ៖** ត្រូវបានធ្វើប្រតិភូកម្មការងារគ្រប់គ្រងសកម្មភាពធ្វើអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ជូនដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តដើម្បីអនុវត្តវិធាន និងបទប្បញ្ញត្តិក្នុងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការជូនដល់ម្ចាស់អាជីវកម្ម។

**ប្រការ ២ ៖** មន្ត្រីជំនាញដែលទទួលបន្ទុកការងារគ្រប់គ្រងអាជីវកម្ម ត្រូវរៀបចំគំរូលិខិតស្នាម ឯកសារបច្ចេកទេស និងអនុវត្តឲ្យបានត្រឹមត្រូវតាមបែបបទ នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ដែលមានចែងក្នុងសេចក្តីណែនាំដោយឡែកសំដៅលើកកម្ពស់ប្រសិទ្ធភាព និងគុណភាព នៃការផ្តល់សេវាសាធារណៈ ក្នុងវិស័យនេះ។

**ប្រការ ៣ ៖** មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហធាតុ ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ផ្ញើជូនក្រសួងដើម្បីជ្រាបជាព័ត៌មាន។

**ប្រការ ៤ ៖** ប្រកាស និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ ៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

Chantholsun

ស៊ុន ចាន់ថុល

**ចម្លងជូន៖**

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អាជ្ញាធរសវនកម្មជាតិ
-អង្គភាពប្រឆាំងអំពើពុករលួយ
-សាលារាជធានី-ខេត្ត (សហការអនុវត្ត)
-ដូចប្រការ ៥ (ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ